ChildSafe
MOVEMENT
TOGETHER, PROTECTING CHILDREN

# គន្លឹះទាំង៧
## សម្រាប់ជួយដល់កុមារ

# ១ សូមពិចារណា!

## រក្សាភពផែនដីដើម្បីសុវត្ថិភាពកុមារ - ការពារបរិស្ថាន

ពេលអ្នកធ្វើដំណើរអ្នកចង់រីករាយនឹងសម្រស់ធម្មជាតិទាំងអស់ដែលប្រទេសមួយអាចផ្តល់ជូន ដូចគ្នាដែរ កុមារនិងប្រជាជនប្រទេសនោះក៏ដូច្នេះដែរ។នៅពេលអនាគតរួមរបស់យើងប្រឈមនឹង ហានិភ័យពីការប្រែប្រួលអាកាសធាតុ ការបំពុលបរិស្ថាន និងផលប៉ះពាល់អវិជ្ជមានផ្សេងៗទៀតដែលបង្កើតដោយមនុស្ស ចូរគិតពីវិធីវិជ្ជមានដែលអ្នកអាចធ្វើ ដើម្បីការពារបរិស្ថាន ដូច្នេះកុមារក៏អាចសាងអនាគតរបស់ពួកគេផងដែរ។

**ពេលអ្នកធ្វើដំណើរ សូមយកចិត្តទុកដាក់ពីសកម្មភាពរបស់អ្នក និងរបៀបដែលវាជះឥទ្ធិពល ដល់បរិស្ថាន ហើយជួយគាំទ្រ គំនិត ផ្តួចផ្តើម ដែលការពារភពផែនដីយើង សម្រាប់កូនៗរបស់យើង។**



# ២ សូមពិចារណា!

## មុននឹងទិញសម្ភារៈ ឬឲ្យលុយទៅកុមារសុំទាន

ការទិញ ឬការដាក់ទានដល់កុមារ មិនមែនជាជម្រើសល្អក្នុងការធ្វើទាននោះទេមានន័យថាអ្នកកំពុងគាំទ្រ ឬទុកពួកគេអោយស្ថិតក្នុងស្ថានភាព ងាយរងគ្រោះនៅតាមដងផ្លូវ មិនបានទៅសាលារៀន និងងាយរងគ្រោះដោយការរំលោភបំពានផ្សេងៗ ការកេងប្រវ័ញ្ច ។ល។ មានអង្គការជាច្រើនកំពុងធ្វើការដើម្បីជួយកុមារ សុំទានអោយចេញផុតពីជីវិតតាមថ្នល់។

**សូមគាំទ្រអង្គការណាដែលការពារកុមារ និង ធានាបានថាកុមារនិងគ្រួសាររបស់ពួកគេមានអនាគតប្រសើរជាងមុន។**



# ៣ សូមធានាថា

## កូនៗរបស់អ្នកមានសុវត្ថិភាព នៅពេលអ្នកបើកបរ

រាងកាយរបស់កុមារមានភាពទន់ខ្សោយណាស់។ ដូច្នេះគ្រោះថ្នាក់ចរាចរណ៍ អាចធ្វើឲ្យកុមារងាយស្លាប់ និងរងរបួសធ្ងន់ ប្រសិនបើអ្នកមិនបានពាក់មួក ឬខ្សែក្រវាត់សុវត្ថិភាពឲ្យកុមារ ពេលអ្នកបើកបរ។

**ការពារកូនៗរបស់អ្នក នៅពេលអ្នកបើកបរម៉ូតូត្រូវពាក់មួកសុវត្ថិភាពឲ្យកូនអ្នក និងនៅពេលបើកបររថយន្ត ត្រូវដាក់កូនអ្នកនៅកៅអីខាងក្រោយ ហើយពាក់ខ្សែក្រវាត់សុវត្ថិភាព។**



# ៤ ស្ទូមរក្សា

## កុមារឲ្យរស់នៅជុំគ្នាក្នុងគ្រួសារប្រសើរជាងឲ្យកុមារទៅរស់នៅក្នុងមណ្ឌលកុមារកំព្រា

មណ្ឌលកុមារកំព្រាមិនមែនសុទ្ធតែជាជម្រើសល្អ សម្រាប់កុមារឡើយ។ មណ្ឌលកុមារកំព្រាជាច្រើន អះអាងថា នឹងផ្តល់អាហារ ការអប់រំ និងការថែទាំដ៏ល្អ ប៉ុន្តែជារឿយៗ មណ្ឌលទាំងនោះមិនគោរពតាមការសន្យាទាំងនោះទេ។ ការបញ្ជូនកុមារទៅរស់នៅក្នុងមណ្ឌលកុមារកំព្រាមានន័យថា ពួកគេឃ្លាតឆ្ងាយពីគ្រួសារ ខ្វះភាពរីករាយ បាត់បង់ ភាពកក់ក្តៅ ពិបាកទទួលសេចក្តីស្រឡាញ់ និងបង្អាក់ការអភិវឌ្ឍន៍របស់កុមារ។ កុមារមាន អនាគតល្អប្រសើរត្រូវតែទទួលការថែទាំក្នុងបរិយាកាសគ្រួសាររបស់ពួកគេ។

**មានអង្គការជាច្រើន កំពុងធ្វើការដើម្បីរក្សាកុមារឱ្យរស់នៅក្នុងគ្រួសារ។ ប្រសិនបើអ្នកដឹងថាមានគ្រួសារណាដែលត្រូវការជំនួយ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារដែលមាននៅក្នុងគន្លឹះលេខ ៧**



# ៥ សូមពិចារណា!

## មុននឹងឲ្យកូនរបស់អ្នកធ្វើចំណាកស្រុក ទៅធ្វើការនៅទីក្រុង ឬក្រៅប្រទេស

កុមារ និងយុវវ័យធ្វើចំណាកស្រុកដើម្បីស្វែងរក ការងារធ្វើ ឬទៅសុំទាន។ជាញឹកញាប់ពួកគេតែងតែត្រូវបានគេកេងប្រវ័ញ្ច រំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និងផ្លូវភេទ។ ភាគច្រើនពួកគេត្រូវបានបង្ខំឲ្យធ្វើការងារដោយ មិនបានលុយ ឬប្រាក់ខែ ទោះបីជាបានចុះកិច្ចសន្យាការងារក៏ដោយ។ សូមប្រាកដថារាល់ការធ្វើចំណាកស្រុករបស់កុមារ ឬគ្រួសារ ត្រូវតែមានព័ត៌មានច្បាស់លាស់ និងត្រៀមខ្លួនជាមុន។

**សូមការពារខ្លួនអ្នក និងមិត្តភ័ក្តិរបស់អ្នក។**

**សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារដែល មាននៅក្នុងគន្លឹះលេខ៧ ដើម្បីទទួលបានព័ត៌មាន ស្តីអំពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព ឬរាយការណ៍ ប្រសិនបើអ្នកសង្ស័យថាជនណាម្នាក់ ត្រូវបានគេ កេងប្រវ័ញ្ច ឬបង្ខំឲ្យធ្វើការងារ។**



# ៦ សូមពិចារណា!

## ពីរវិធី ការពារកុមារឲ្យរួចផុតពីការកេងប្រវ័ញ្ច និងការរំលោភបំពានផ្លូវភេទ

កុមារប្រឈមមុខខ្ពស់នឹងការបំពានផ្លូវភេទ ការបោកប្រាស់យកទៅលក់ ដោយជនដែលស្គាល់ និងជឿទុកចិត្តទៅឲ្យធ្វើពេស្យាចារដែលធ្វើឲ្យរងការប៉ះទង្គិចផ្លូវកាយនិងផ្លូវចិត្តធ្ងន់ធ្ងរ។ ការពារកុមារនៅក្នុងសហគមន៍របស់អ្នក និងរាយការណ៍នៅពេលដែលសង្ស័យថាមានករណី រំលោភបំពានកុមារ។

**ការរួមភេទជាមួយកុមារជាអំពើខុសច្បាប់។ នៅពេលដែលអ្នកទៅកន្លែងកម្សាន្តដូចជា ភោជនីយដ្ឋាន ក្លឹប ខារ៉ាអូខេ ជៀសវាងរួមភេទ ជាមួយកុមារព្រោះអ្នកអាចប្រឈមមុខនឹងការជាប់ពន្ធនាគារ។**



# ៧ សូមពិចារណា!

## ពីវិធីការពារកុមារ ឲ្យរួចផុតពី ការរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត និង ការមិនយកចិត្តទុកដាក់

កុមារជាច្រើនក្នុងប្រទេសកម្ពុជានៅតែរងការវាយដំលើរាងកាយ ការគម្រាមកំហែងហើយមិនត្រូវបានគេយកចិត្តទុកដាក់ និង ថែទាំដឹតដល់នៅពេលមានជំងឺ ឬស្ថិតក្នុងស្ថានភាពរំលោភបំពានផ្សេងៗ។

**ប្រសិនបើអ្នកឃើញ ឬសង្ស័យករណីរំលោភបំពានផ្លូវកាយ ផ្លូវចិត្ត ឬការមិនយកចិត្តទុកដាក់ សូមទាក់ទងមកលេខទូរស័ព្ទសុវត្ថិភាពកុមារ(២៤ម៉ោង)៖**

| | |
|---|---|
| (ភ្នំពេញ) | **012 311 112**<br>**010 311 220** |
| (សៀមរាប) | **017 358 758** |
| (ព្រះសីហនុ) | **012 478 100**<br>**016 478 100** |
| (កំពត) | **010 333 296** |
| (កំពង់ចាម) | **012 557 188** |
| (ប៉ោយប៉ែត) | **095 960 303** |
| (អ្នកលឿង) | **089 500 008** |
| (បាត់ដំបង) | **092 911 115** |
| (ប៉ូលិសអន្តរាគមន៍បន្ទាន់) | **023 997 919**<br>**1288** |



ស្វែងយល់បន្ថែមពី

ChildSafe MOVEMENT

TOGETHER, PROTECTING CHILDREN

https://thinkchildsafe.org

គាំទ្រដោយ

friends international

Together, building futures.